# កក់ប្រកបដោយអ្នកបកប្រែ

Multicultural Communities Council of South Australia

ប្រសិនបើអ្នកមិនមែនជាអ្នកនិយាយភាសាអង់គ្លេសទេ ហើយត្រូវការទាក់ទងនិងសេវាសង្គ្រោះបន្ទាន់ អ្នកអាចទូរសព្ទទៅសេវាកម្មបកប្រែសរសេរនិងនិយាយថ្នាក់ជាតិ(TIS National)តាមទូរសព្ទលេខ 131 450 ហើយសុំឲ្យគេភ្ជាប់ទៅសេវាសង្គ្រោះបន្ទាន់របស់រដ្ឋអូស្ត្រាលីខាងត្បូង (SA SES)។ សេវានេះឥតមានគិតថ្លៃ ហើយមាន 24 ម៉ោងក្នុងមួយថ្ងៃ។

1. ពេលអ្នកហៅទៅ TIS National ចម្លើយស្វ័យប្រវត្តមួយនឹងសួរថាអ្នកត្រូវការភាសាអ្វី។ សូមសូត្រឈ្មោះភាសាដែលអ្នកត្រូវការ(ខ្មែរ)។
2. ពេលអ្នកត្រូវបានភ្ជាប់ទៅទូរសព្ទការីរបស់ TIS National ហើយ សូមនិយាយប្រាប់ការីនោះនូវឈ្មោះភាសាម្តងទៀត។
3. ចូររង់ចាំក្នុងទូរសព្ទ ក្នុងខណៈទូរសព្ទការីកំពុងស្វែងរកអ្នកបកប្រែដែលទំនេរជូនអ្នក។

ទូរសព្ទការីនោះនឹងភ្ជាប់អ្នកជាមួយអ្នកបកប្រែដែលនិយាយភាសាដែលអ្នកបានសុំ។ បន្ទាប់ទៅ អ្នកនឹងត្រូវបានសុំឲ្យផ្តល់ ៖

- ឈ្មោះរបស់អ្នក
- ឈ្មោះរបស់ស្ថាប័នដែលអ្នកត្រូវការទាក់ទង
- លេខទូរសព្ទរបស់ស្ថាប័នដែលអ្នកត្រូវការទាក់ទង។.

ចំពោះជំនួយសង្គ្រោះបន្ទាន់ក្នុងវិស័យទឹកជំនន់និងខ្យល់ព្យុះ គេអាចទាក់ទង SES តាមលេខ 132 500

- ការខូចខាតផ្ទះធ្ងន់ធ្ងរ
- ទ្រព្យសម្បត្តិអាចរងការខូចខាតដោយទឹកជំនន់
- ដើមឈើបាក់កិនលើរថយន្តឬផ្ទះ

ចំពោះព័ត៌មានក្នុងខណៈមានឧបត្តិហេតុធាតុអាកាសធំដុំដូចជា ខ្យល់ព្យុះ ទឹកជំនន់ រលកកំដៅ ឬក៏ភ្លើងឆេះព្រៃ សូមហៅទៅខ្សែទូរសព្ទរហ័ស លេខ 1800 362 361
ក្នុងគ្រាអាសន្នដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិត នៅពេលអ្នកត្រូវការចម្លើយបន្ទាន់ពីប៉ូលិស ឬឡានទឹក ឬឡានពេទ្យ ចូរហៅទៅលេខ 000

ចូររង់ចាំក្នុងទូរសព្ទក្នុងខណៈទូរស័ព្ទការីធ្វើការភ្ជាប់អ្នកនិងអ្នកបកប្រែទៅស្ថាប័ននោះ។

ដើម្បីមើលសារនេះ ឬព័ត៌មានពាក់ពន្ធដទៃ សូមចូលទៅ
www.tisnational.gov.au និង www.sa.gov.au
គាំពារដោយ Multicultural Communities Council of SA

Australian Government
Department of Home Affairs

TIS TRANSLATING AND INTERPRETING SERVICE

Multicultural Communities Council of South Australia
113 Gilbert Street, Adelaide SA 5000
**PHONE** (08) 8345 5266
**E** mccsa@mccsa.org.au
**www.mccsa.org.au**